ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦២២ (ប្រក) កសក

នាយកដ្ឋាន ផលិតកម្ម & បសុព្យាបាល
ចូល
លេខ ...5788..........
ថ្ងៃទី...16...11...10.....
ម៉ោង....................

# ប្រកាស

## ស្តីពី

## ប្រភេទត្រា ឬ ស្លាកបសុពេទ្យសម្រាប់សម្គាល់ ការត្រួតពិនិត្យអនាម័យសាច់ និង ផលិតផលសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូត្រសាស្ត្រ និង កែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង ការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

-បានឃើញអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និង ផលិតផលសត្វ

-យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះកំណត់ការបង្កើត និង ការប្រើប្រាស់ប្រភេទត្រាបសុពេទ្យ សម្រាប់អូសលើផ្ទាំងសាច់ និង ប្រភេទស្លាកបសុពេទ្យ សម្រាប់បិទសម្គាល់លើកញ្ចប់សាច់ និង ផលិតផលសត្វ ក្នុងគោលបំណងបញ្ជាក់នូវសុវត្ថិភាព និង អនាម័យសាច់ និង ផលិតផលសត្វ ។

**ប្រការ ២ :** អនុញ្ញាតឱ្យនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល បង្កើត និង ប្រើប្រាស់ត្រាបសុពេទ្យសម្រាប់អូសលើផ្ទាំងសាច់ និង ស្លាកបសុពេទ្យ សម្រាប់បិទសម្គាល់លើកញ្ចប់សាច់ និង ផលិតផលសត្វ ។

អត្តសញ្ញាណនៃត្រា និង ស្លាកបសុពេទ្យ ត្រូវកំណត់ក្នុងឧបសម្ព័ន្ធទី១ និង ទី២ នៃប្រកាសនេះ ។

**ប្រការ ៣ :** ភ្នាក់ងារបសុពេទ្យ ដែលមានសមត្ថកិច្ចប្រចាំការនៅសត្តឃាតដ្ឋានរាជធានី ខេត្ត ត្រូវបានប្រគល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ត្រា និងស្លាកបសុពេទ្យ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ យោងតាមសំណើរបស់ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

**ប្រការ ៤ :** នៅពេលប្រគល់សិទ្ធិឱ្យកាន់កាប់ និង ប្រើប្រាស់ត្រា ឬ ស្លាកបសុពេទ្យ ដល់ភ្នាក់ងារបសុពេទ្យមានសមត្ថកិច្ច នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ត្រូវធ្វើកំណត់ហេតុ ភ្ជាប់ស្នាមគំរូត្រា ឬ ស្លាកបសុពេទ្យដែលត្រូវប្រើប្រាស់តាមរាជធានី ខេត្ត ដើម្បីតំកល់ជាភស្តុតាងនៅក្រសួងមហាផ្ទៃ សាលាដំបូងរាជធានី ខេត្ត សាមី ។

**ប្រការ ៥ :** មន្ត្រីភ្នាក់ងារបសុពេទ្យ ដែលបានទទួលសិទ្ធិកាន់កាប់ប្រើប្រាស់ត្រា និង ស្លាកបសុពេទ្យ ត្រូវទទួលខុសត្រូវក្នុងការប្រើប្រាស់ស្របតាមលក្ខណៈវិនិច្ឆ័យបច្ចេកទេស និង នីតិវិធីច្បាប់ ។

ក្នុងករណីមានការផ្ទេរសិទ្ធិកាន់កាប់ និង ប្រើប្រាស់ត្រា និង ស្លាកបសុពេទ្យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ត្រូវធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចេញសេចក្តីសម្រេចប្រគល់សិទ្ធិជាថ្មី ។

**ប្រការ ៦ :** ក្នុងករណីបាត់ត្រា និង ស្លាកបសុពេទ្យ ភ្នាក់ងារបសុពេទ្យ ត្រូវរាយការណ៍បន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធដែលនៅជិតបំផុត ដើម្បីចាត់វិធានការផ្លូវច្បាប់ និង ត្រូវរាយការណ៍តាមឋានានុក្រម មកប្រធាន នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់។

ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ត្រូវរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អំពីហេតុការណ៍នេះ និង ស្នើសុំបដិសេធ និង សុំបង្កើតត្រា ឬ ស្លាកបសុពេទ្យថ្មី ដើម្បីប្រើប្រាស់។

**ប្រការ ៧ :** ភ្នាក់ងារបសុពេទ្យណាដែលធ្វើឱ្យបាត់ត្រាដោយចេតនា ឬ យកត្រា ឬ ស្លាកបសុពេទ្យ ទៅប្រើប្រាស់ខុសច្បាប់ ឬ ផ្ទុយនឹងលក្ខណៈវិនិច្ឆ័យ ក្នុងការបញ្ជាក់អនាម័យសាច់ និង ផលិតផលសត្វ ត្រូវទទួលទោសតាមច្បាប់ពាក់ព័ន្ធជាធរមាន។

**ប្រការ ៨ :** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩ :** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ ប្រធានមន្ទីរកសិកម្ម និងប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាល រាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី.១០......ខែ..វិច្ឆិកា.....ឆ្នាំ ២០១០

រដ្ឋមន្ត្រី

ចាន់ សារុន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ

ត្រាសម្រាប់គូសលើថ្នាំងសាច់



ឧបសម្ព័ន្ធ ១ ភ្ជាប់ប្រកាសលេខ...៦២២...ប្រក.កសក
ចុះថ្ងៃទី...១០......ខែ...វិច្ឆិកា...ឆ្នាំ ២០១០

## អត្តសញ្ញាណត្រា សម្រាប់អូសសម្គាល់លើផ្ទាំងសាច់

អត្តសញ្ញាណត្រា សម្រាប់អូសសម្គាល់លើផ្ទាំងសាច់ ត្រូវបានកំណត់ដូចខាងក្រោម ÷

- ធ្វើពីស្ពាន់ ជារូបឡូរុញ មានជក់អេប៉ុងនៅពីលើសម្រាប់បញ្ចេញទឹកថ្នាំត្រាពណ៌ខៀវ ភ្ជាប់ទៅជាមួយនឹងដងឈើ ដែលមានប្រវែង ២៥ (ម្ភៃប្រាំ) សង់ទីម៉ែត្រ
- មុខកាត់ត្រានេះ មានអង្កត់ផ្ចិតមុខកាត់ ៨០ (ប៉ែតសិប) មីលីម៉ែត្រ កម្ពស់៣០ (សាបសិប) មីល្លីម៉ែត្រ
- នៅលើផ្ទៃរូឡូ មានសញ្ញាពេទ្យ ដែលបន្តដោយអក្សរមូល **ត្រួតពិនិត្យអនាម័យ** ខណ្ឌដោយចំណុចចុចមូលមួយ រួចមានអក្សរមូល " **ក.ផ.ប** " រួចខណ្ឌដោយចំណុចចុចមូលមួយទៀត រួចសរសេរអក្សរមូលកាត់ឈ្មោះរាជធានី ខេត្ត **រ.ត, ក.ណ, ស.រ** នៅលើសាច់ ប្រើចំណុចចុចមូលមួយទៀត ដាក់លេខកូដ និង សញ្ញាពេទ្យមួយទៀត ដោយកម្ពស់អក្សរ ៩ (ប្រាំបួន) មីលីម៉ែត្រ ដូចមានគំរូបង្ហាញខាងក្រោម:

(✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.ក.ណ.០១✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.ក.ណ.០១✚)

(✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.រ.ត.០២✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.រ.ត.០២✚)

(✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.ស.រ.០៣✚ ត្រួតពិនិត្យអនាម័យ.ក.ផ.ប.ស.រ.០៣✚)

ឧបសម្ព័ន្ធ ២ ភ្ជាប់ប្រកាសលេខ...៦២៧...ប្រក.កសក
ចុះថ្ងៃទី...១០...ខែ...ធ្នូ...ឆ្នាំ ២០១០

## អត្តសញ្ញាណស្លាកបសុពេទ្យ សម្រាប់
## បិទសម្គាល់លើកញ្ចប់សាច់ និង ផលិតផលសត្វ

ស្លាកបសុពេទ្យ ធ្វើពីក្រដាសស្អិតអាចបកបិទបាន រាងចតុកោណកែង មានបណ្តោយប្រវែង ៤០(សែសិប) មីល្លីម៉ែត្រ មានទទឹងប្រវែង ២៥(ម្ភៃប្រាំ)មីល្លីម៉ែត្រ ផ្ទៃក្រដាសពណ៌ស អក្សរពណ៌ទឹកប៊ិក។ នៅក្នុងផ្ទៃក្រដាស ស្របតាមបណ្តោយ មានសរសេរអក្សរមូលពីរជួរ នៅផ្នែកខាងលើគឺ **ត្រួតពិនិត្យអនាម័យ**។ នៅផ្នែកខាងក្រោម មានសរសេរអក្សរកាត់ **ក.ផ.ប** សរសេរឈ្មោះរាជធានី ខេត្ត និង លេខកូដ ដូចមានគំរូបង្ហាញខាងក្រោម៖

40 ម.ម × ២៥ ម.ម

**ត្រួតពិនិត្យអនាម័យ**
**ក.ផ.ប.ក.ណ.០១**

៤០ ម.ម × ២៥ ម.ម

**ត្រួតពិនិត្យអនាម័យ**
**ក.ផ.ប.រ.ក.០២**

៤០ ម.ម × ២៥ ម.ម

**ត្រួតពិនិត្យអនាម័យ**
**ក.ផ.ប.ស.រ.០៣**

ឧបសម្ព័ន្ធ ៣ ភ្ជាប់ប្រកាសលេខ...៦៩២...ប្រក.កសក
ចុះថ្ងៃទី...១០...ខែ...មិថុនា...ឆ្នាំ ២០១០

## រូបមន្តលាយទឹកថ្នាំពណ៌សម្រាប់បោះត្រាលើផ្ទាំងសាច់

ទឹកថ្នាំពណ៌សម្រាប់បោះត្រាលើផ្ទាំងសាច់ ត្រូវបានផ្សំឡើងពីសារធាតុពិសេស ដែលអាចឱ្យមើលឃើញយ៉ាងច្បាស់ ជាប់បានយូរ និងគ្មានជាតិពុល ។ ទឹកថ្នាំពណ៌ និងរូបមន្តសម្រាប់លាយ ត្រូវបានកំណត់ដូចខាងក្រោម:

- រូបមន្តទឹកថ្នាំពណ៌ខៀវ

| | |
|---|---|
| មេទីឡែន (methylene blue) | ចំនួន ៧ ក្រាម |
| អាល់កុល ៩០ អង្សា | ចំនួន ១០០ ក្រាម |
| គ្លីសេរីន (Glycerine) | ចំនួន ៥០ ក្រាម |
| ទឹក | ចំនួន ៥០០ ក្រាម |

- រូបមន្តទឹកថ្នាំពណ៌ក្រហម

| | |
|---|---|
| អាស៊ីតហ្វ៊ុកស៊ីន (Fuchsine acid) | ចំនួន ៧ ក្រាម |
| អាល់កុល ៩០ អង្សា | ចំនួន ១០០ ក្រាម |
| គ្លីសេរីន (Glycerine) | ចំនួន ៥០ ក្រាម |
| ទឹក | ចំនួន ៥០០ ក្រាម |